ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ០០២ ដ.ន.ស / អ.ស.ណ

ភ្នំពេញ, ថ្ងៃទី ៦ ខែ ០៧ ឆ្នាំ ២០០០

# សារាចរណែនាំ

## ស្តីពី

## ការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគំរោងប្លង់ និង សាងសង់ របស់សហគ្រាស ក្រុមហ៊ុន និង រូបវ័ន្តបុគ្គលបរទេស

យោងមាត្រាទី ១៩ ត្រង់ផ្នែកទី ៤ នៃច្បាប់ស្តីពី " វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម " ដែលចែងពី ក្រុមហ៊ុនបរទេស ដែលមានតែសាខា ឬ ទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា និង យោងតាមប្រកាសលេខ ៧៥ ប្រក / ដ.ន.ស ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សូមធ្វើការណែនាំ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម របស់បណ្តាសហគ្រាស ក្រុមហ៊ុន និងរូបវ័ន្តបុគ្គលបរទេសដូចតទៅ :

I ការកំណត់ទ្រង់ទ្រាយ

សហគ្រាស ក្រុមហ៊ុន រូបវ័ន្តបុគ្គលបរទេស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបាន បែងចែកតាមទ្រង់ទ្រាយអាជីវកម្មដូចតទៅ :

១-សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានទីស្នាក់ការធំនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣-រូបវ័ន្តបុគ្គលបរទេសសិក្សាគំរោងប្លង់

II ការចុះបញ្ជីប្រកបអាជីវកម្ម

ចំពោះ :

១- អភិបាលការិយាល័យតំណាង ឬ ទីភ្នាក់ងារ និង សាខាក្រុមហ៊ុន ឬ អាណត្តិគាហកនៃ សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានការិយាល័យតំណាង ទីភ្នាក់ងារ និង សាខាក្នុងព្រះរាជាណាចក្រកម្ពុជា